**សិក្ខាសាលាពិគ្រោះយោបល់លើ**

**សេចក្តីព្រាងផែនការសកម្មភាពឆ្លើយតបការប្រែប្រួលអាកាសធាតុសម្រាប់វិស័យព័ត៌មាន**

សណ្ឋាគារសុខាភ្នំពេញ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥

**សុន្ទរកថា**

**របស់ក្រសួងបរិស្ថាន**

**ថ្លែងដោយលោក ជា ចន្ទន៍តូ អនុប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ**

- *សូមគោរពឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន*
- *សូមគោរពឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ដែលបានអញ្ជើញចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់នាថ្ងៃនេះជាទីមេត្រី*

ជាបឋម ជូសមុខឱ្យឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានសេចក្តីសោមនស្សរីករាយ និងសូមអរគុណចំពោះថ្នាក់ដឹកនាំក្រសួងព័ត៌មាន ដែលបានអញ្ជើញក្រសួងបរិស្ថានមកចូលរួមក្នុង **"សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័យព័ត៌មាន"** ដ៏មានសារៈសំខាន់នាព្រឹកនេះ។ សិក្ខាសាលានេះជាជំហានចាំបាច់មិនអាចខ្វះបាន សម្រាប់ផ្តល់ឱកាសជូនគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ពិនិត្យ ផ្តល់យោបល់លើសេចក្តីព្រាងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័យព័ត៌មាន ហើយដែលនេះជាលើកទី២ ហើយ ដែលក្រសួងបរិស្ថាន និងក្រសួងព័ត៌មាន បានសហការរួមគ្នាក្នុងក្របខ័ណ្ឌការងារប្រែប្រួលអាកាសធាតុ បន្ទាប់ពីការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់អ្នកសារព័ត៌មាន ដែលបានធ្វើនៅចុងឆ្នាំ២០១៣ កន្លងមក។

ការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាប្រឈមដ៏ពិតប្រាកដមួយសម្រាប់ប្រទេសកម្ពុជា ដូចដែលយើងទាំងអស់គ្នាបានសង្កេតឃើញជាក់ស្តែងនូវព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតី កាន់តែញឹកញាប់ និងធ្ងន់ធ្ងរជាងមុន ដូចជាគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ។ល។ ដែលបង្កឱ្យមានការបាត់បង់អាយុជីវិតមនុស្សសត្វ ខូចខាតហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បាត់បង់ថវិកា ប៉ះពាល់លើសេដ្ឋកិច្ច-សង្គម និងជីវភាពប្រជាជន។ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងជាប្រធានកិត្តិយសនៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ បានទទួលស្គាល់ពេញលេញ អំពីភាពចាំបាច់បន្ទាន់នៃការចាត់វិធានការឆ្លើយតបនឹងការបញ្ហាដ៏ប្រឈមនេះ ដើម្បីជានាឱ្យមានការអភិវឌ្ឍដោយចីរភាពនៅក្រោមលក្ខខណ្ឌប្រែប្រួលអាកាសធាតុ។

ដូចឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់បានជ្រាបថា កាលពីថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅវិមានសន្តិភាព ក្នុងឱកាសនៃពិធីបើកវេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ **ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា២០១៤-២០២៣** ដែលជាត្រីវិស័យសម្រាប់ដឹកនាំការរៀបចំផែនការសកម្មភាពឆ្លើយតបនឹងបញ្ហាប្រែប្រួលអាកាសធាតុនៅកម្ពុជា នៅក្នុងគ្រប់វិស័យ។

ផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនេះ ត្រូវបានរៀបរៀងឡើងក្នុងក្របខណ្ឌយុទ្ធសាស្ត្រប្រទាក់គ្នា ដើម្បីដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុនៅកម្ពុជា តាមរយៈវិធានការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការអភិវឌ្ឍដោយបញ្ចេញកាបូនតិច ក៏ដូចជាវិធានការកសាងសមត្ថភាព អប់រំផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹង។ បច្ចុប្បន្នក្រសួងបរិស្ថានកំពុងសម្របសម្រួល និងផ្តល់ការគាំទ្រដល់ក្រសួងស្ថាប័នចំនួន១៤ រួមទាំងក្រសួងព័ត៌មាន ក្នុងការរៀបចំផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ។ យើងបានផ្តល់សារៈសំខាន់ខ្ពស់ចំពោះ ការងារផ្សព្វផ្សាយស្តីពីការប្រែប្រួលអាកាសធាតុ ដោយហេតុថា ការយល់ដឹងរបស់សាធារណជនស្តីពីបញ្ហាប្រែប្រួលអាកាសធាតុនៅមានកំរិត ហើយយោងតាមការសិក្សាស្រាវជ្រាវរបស់ក្រសួងបរិស្ថាន មានប្រជាពលរដ្ឋកម្ពុជាចំនួន៥៩% បានទទួលព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុពីទូរទស្សន៍ ៥២% ទៀតពីវិទ្យុ ហើយកាសែត ទស្សនាវដ្តី និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀតក៏បានដើរតួយ៉ាងសំខាន់ក្នុងការរួមចំណែកផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។ ក្នុងន័យនេះ ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័យព័ត៌មាន ដែលនឹងត្រូវអនុម័តនាពេលខាងមុខនេះ នឹងក្លាយជាឯកសារផែនការដ៏សំខាន់មិនអាចខ្វះបាន ក្នុងការកំណត់គម្រោងប្រែប្រួលអាកាសធាតុអាទិភាពក្នុងវិស័យព័ត៌មាន និងការកៀរគរធនធានសម្រាប់គាំទ្រការអនុវត្តដាក់ស្តែង។

ខ្ញុំសូមជម្រាបថា នាពេលថ្មីៗនេះ ដៃគូអភិវឌ្ឍន៍យើងក្រោមកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា រួមមាន កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ សហភាពអឺរ៉ុប និងរដ្ឋាភិបាលស៊ុយអែត បានឯកភាពផ្តល់ថវិកាជំហានទី២ ដែលក្នុងនោះ ទឹកប្រាក់ចំនួន៣,៦លានដុល្លារអាមេរិក ត្រូវបានអនុម័តជាស្រេច សម្រាប់គាំទ្រដល់ការអនុវត្តគម្រោងអាទិភាពនៅក្នុងផែនការសកម្មភាពរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ ដែលបានអនុម័តរួចហើយ។ នេះមានន័យថា បន្ទាប់ពី

ទទួលការអនុម័តជាផ្លូវការរួចហើយ ក្រសួងព័ត៌មានអាចរៀបចំសំណើគម្រោង ដើម្បីដាក់សុំហិរញ្ញប្បទានសម្រាប់អនុវត្តបន្ត។

ជាទីបញ្ចប់ ខ្ញុំសូមចូលរួមអបអរសាទរ និងថ្លែងអំណរគុណជាពិសេស ជូនចំពោះឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មាន ឯកឧត្តមរដ្ឋលេខាជាសមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ដែលបានផ្តល់ការគាំទ្រ និងកិច្ចសហប្រតិបត្តិការយ៉ាងពេញទំហឹងជាមួយក្រសួងបរិស្ថាន។ សូមអរគុណដ៏ស្មោះចំពោះក្រុមការងាររៀបចំផែនការសកម្មភាពឆ្លើយតបការប្រែប្រួលធាតុ ដែលបានដឹកនាំការរៀបចំផែនការនេះប្រកបដោយជោគជ័យ។ ខ្ញុំសូមជូនពរឱ្យអង្គសិក្ខាសាលានេះប្រព្រឹត្តទៅដោយជោគជ័យ និងសូមប្រសិទ្ធិពរជូនឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ នូវពុទ្ធិពរទាំងបួនប្រការកុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ